កម្មសិទ្ធិរបស់ក្រុមមេធាវី
កម្ពុជា អន្តរជាតិ
PROPERTY OF CILF

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៧ លេខ ៥៣ សប្តាហ៍ទី ៣ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧

រាជកិច្ច

ផ្សាយចេញពី
ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

កម្មសិទ្ធិរបស់ក្រុមមេធាវី
កម្ពុជា អន្តរជាតិ
PROPERTY OF CILF

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៩-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/២០៥ ស្ដីពីការតែងតាំង សម្ដេច **ចៅសែន កុសល ឈុំ** ជា ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ៥២១៧

១០-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៨១ ស្ដីពីការតែងតាំង លោក **ខៀវ ម៉ារ៉ាឌី**, លោក **ទន្សា ឈាន** និង លោក **ជា ឌី** ជា ឧកញ៉ា ៥២១៨

១០-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៨២ ស្ដីពីការតែងតាំង លោកស្រី **រុណា ម៉ារីណា** ជា ឧកញ៉ា ៥២១៩

១០-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៨៣ ស្ដីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **កែវ សុន្ធា** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៥២២០

១០-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៨៤ ស្ដីពីការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ចំពោះសព ឯកឧត្តម **អ៊ិន នាង** នូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ៥២២១

II.ក្រុមប្រឹក្សាធម្មនុញ្ញ

សេចក្ដីសម្រេច

១០-៧-២០០៧ -សេចក្ដីសម្រេចលេខ០៩២/០០៣/២០០៧កបធ.ច ចុះថ្ងៃទី១០ខែកក្កដាឆ្នាំ ២០០៧ ៥២២២

III.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

១២-៧-២០០៧ -អនុក្រឹត្យលេខ ៧០ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៥២២៤

១០-៧-២០០៧ -អនុក្រឹត្យលេខ ៥២៣ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥២២៦

១០-៧-២០០៧ -អនុក្រឹត្យលេខ ៥២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥២២៧
១០-៧-២០០៧ -អនុក្រឹត្យលេខ ៥២៥ អនក្រ.តត ស្តីពីការសំរួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៥២២៩
១១-៧-២០០៧ -អនុក្រឹត្យលេខ ៥២៦ អនក្រ.តត ស្តីពីការសំរួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៥២៣១
១២-៧-២០០៧ -អនុក្រឹត្យលេខ ៥២៧ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិ ៥២៣៣
១២-៧-២០០៧ -អនុក្រឹត្យលេខ ៥២៨ អនក្រ.តត ស្តីពីការតែងតាំង និង ប្រគល់ភារកិច្ចមន្ត្រីរាជការ ៥២៣៤
១២-៧-២០០៧ -អនុក្រឹត្យលេខ ៥២៩ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥២៣៥
១២-៧-២០០៧ -អនុក្រឹត្យលេខ ៥៣០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥២៣៦
១២-៧-២០០៧ -អនុក្រឹត្យលេខ ៥៣១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥២៣៧
១២-៧-២០០៧ -អនុក្រឹត្យលេខ ៥៣២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥២៣៩
១២-៧-២០០៧ -អនុក្រឹត្យលេខ ៥៣៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥២៤០
១២-៧-២០០៧ -អនុក្រឹត្យលេខ ៥៣៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥២៤២

២-សេចក្តីសំរេច

១០ -៧-២០០៧ -សេចក្តីសំរេចលេខ ៣៤ សសរ ស្តីពីការចាត់តាំងមន្ត្រីរាជការ ៥២៤៤
១០ -៧-២០០៧ -សេចក្តីសំរេចលេខ ៣៥ សសរ ស្តីពីការចាត់តាំងសមាសភាពក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈជាតិនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និង ជួយជនរងគ្រោះដោយសារការជួញដូរ ៥២៤៥

IV-ការិយាល័យក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១-ប្រកាស

១២-៦-២០០៧ -ប្រកាសលេខ ៤៦៥ សហវ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ ២០០៧ (*ត មកពីរាជកិច្ច លេខ ៤៩,៥០,៥១,៥២*) ៥២៤៩

២-សេចក្តីជូនដំណឹង

២៩-៦-២០០៧ -សេចក្តីជូនដំណឹងលេខ ០១២ សហវ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៧ ៥២៥៥

កម្មសិទ្ធិរបស់ក្រុមមេធាវី
កម្ពុជា អន្តរជាតិ
PROPERTY OF CILF

២.ធនាគារជាតិ នៃកម្ពុជា

ប្រកាស

១៦-៧-២០០៧ -ប្រកាសលេខ ធ៧.០៧.១១០ ប្រក ស្តីពីបទបញ្ជានៃការដឹកជញ្ជូនធនប័ត្រ ៥២៥៦

៣.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១១-៧-២០០៧ -ប្រកាសលេខ ៦៨៦ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុនទីប អីមរខេ បង្កើត
រោងចក្រ "ផលិតបំពង់ទីបដែកអ៊ីណុក" ដែលមានឈ្មោះថា "ទីប អីមរខេ" ៥២៩៩

៤.ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

ប្រកាស

០៣-៧-២០០៧ -ប្រកាសលេខ ២៦៣ស.អ.យ ស្តីពីលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុ របស់អ្នកសុំដី
សម្បទានសង្គមកិច្ច ៥៣០១

៥.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៦៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទូ សុន (ខេមបូឌា)** ៥៣០៦
១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៦៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.អេ.អ៊ីមផត អិចផត
អេន ខនស្ត្រាក់ស៊ិន** ៥៣០៨
១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៧០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាន់ ឈីខ្មែរ ឌីវេ
ឡុបមេន អិនធើណេសិនណល** ៥៣១០
១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **កម្ពុជា អេជី ខបភើ
រេសិន** ៥៣១២
១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច ស៊ី ស៊ី អ៊ិន
វេសមេន ខូ អិលធីឌី** ៥៣១៤

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តោ សំរឿន ឌីវេឡុបមេន ខូ អិលធីឌី** ៥៣១៦

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខ្មែរ ពាណិជ្ជ** ៥៣១៨

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៧៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចី ឃូ ១ ធី** ៥៣២០

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្រ៊ុន ហ៊ារ អាម៉ា អាំងឌុយស្ទ្រី** ៥៣២២

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃ្លោលជេន អេគ្រីខលឈ័រ ឌីវេឡុបមេន គ្រុប** ៥៣២៤

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៨២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នាទូឡូមូច អ៊ិនវេសមេន & ឌីវេឡុបមេន** ៥៣២៦

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៨៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មីច អ៊ិនវេសមេន ខូ អិលធីឌី** ៥៣២៨

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៨៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាំង សុន ខបតើរេសិន** ៥៣២៩

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៨៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉េនឡៀន អិនធើណេសិនណាល ហ្គោមីច អិលធីឌី** ៥៣៣១

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៨៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផេតខម ខូ អិលធីឌី** ៥៣៣៣

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៨៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាជេស្ទីក អ៊ិធើណេសិនណាល ហ្គោមីច អិលធីឌី** ៥៣៣៥

កម្មសិទ្ធិរបស់ក្រុមមេធាវី
កម្ពុជា អន្តរជាតិ
PROPERTY OF CILF

១៦-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចឹង ផេង អ៊ីមផត អិចផត** ៥៣៣៧

១៦-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៩០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រស្មី សម្បត្តិ រតនៈ ខូ អិលធីឌី** ៥៣៣៩

១៦-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៩៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លី យូហាំរ អភិវឌ្ឍន៍** ៥៣៤១

១៦-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី សៀកខេងអភិវឌ្ឍន៍** ៥៣៤៣

១៦-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លី សីហា អភិវឌ្ឍន៍** ៥៣៤៥

១៦-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៩៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្លូបល យ៉ប ស៊ើវិស** ៥៣៤៧

១៦-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៩៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នូឌីស្ត (ខេមបូឌា) ខូ អិលធីឌី** ៥៣៤៩

១៦-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ្រេនដ៍ ស៊ីល្វសិន (ខេមបូឌា) លីមីធីត** ៥៣៥១

១៦-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៨០០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីន ឈុន (ខេមបូឌា) ខូ អិលធីឌី** ៥៣៥៣

១៩-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៨០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីន ហ្វា(ខេមបូឌា) អ៊ិនធើណេសិណល អ៊ិនវេសមេន គ្រុប ខូ អិលធីឌី** ៥៣៥៥

ព្រះរាជក្រឹត្យ

នស/រកត/០៥០៧/២០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

សម្តេច ចៅសែន កុសល ឈុំ

ជា

ឧត្តមប្រឹក្សាផ្ទាល់
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

នរោត្តម សីហមុនី

៣រ.ល.០៧០៥.២១៧

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៧

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០០៩/០៧ រ.ចត
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៧
សម្តេចចៅហ្វាវាំង វរៀងជ័យ អធិបតីស្រីឧង
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

គង់ សំអុល

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/២៨១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

១-លោក ឡៀប ម៉ូរ៉ាឌី
២-លោក ចន្ទ ឈាង
៣-លោក ជា នី

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ/ល.០៧០៧.២៩៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

លេខ ៨៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/២៨២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោកស្រី រុណា ម៉ារីណា

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៧០៧.២៩៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

លេខៈ ៤៨៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/ ២៨៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **កែវ សុខ្ញា** អត្តលេខ ០៣៩៤ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣ល.០៧០៧.២៩៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

លេខ ២៧៥ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ប៊ុន ជីនកេន

នស/រកត/០៧០៧/២៨៤

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ ចំពោះ

សព ឯកឧត្តម អ៊ុន នាង

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៧.៣០០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

លេខ ២៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ :១៣១ /០០៣ /២០០៧

ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧

សេចក្តីសម្រេច

លេខ :០៩២/០០៣/២០០៧ កបធ.ច

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជសារ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ វេលាម៉ោង ១៤ និង ៣០ នាទី ។

ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាសម្រេចតាមច្បាប់ហើយ

- យល់ឃើញថា ព្រះរាជសាររបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ បានធ្វើឡើងត្រឹមត្រូវតាមមាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា១៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។
- យល់ឃើញថា មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋបានចែងថា " ចំពោះបទឧក្រិដ្ឋ និងបទឧក្រិដ្ឋតម្រូវឱ្យធ្វើការ ចៅក្រមមិនត្រូវគិតពីស្ថានភាពបន្ធូរទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមា ឬព្យួរទោសបានឡើយ ។ ចំពោះបទមជ្ឈិមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ អាចត្រូវព្យួរទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើស មិនត្រូវទទួលរង

ទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្តាមាត្រាមុនៗក្នុងរយៈពេល ៥ ឆ្នាំ ក្រោយពីការកាត់ទោសរបស់ខ្លួន "។

- យល់ឃើញថា មាត្រា ៨ នេះ កែប្រែតែមាត្រា ៧០ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល **ពុំមានប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍កុមារឡើយ** ។ បទបញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋខាងលើនេះ ពុំមានអធម្មនុញ្ញភាពទេ ។
- យល់ឃើញថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់ ។ ពាក្យថាច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

សម្រេច

មាត្រា ១.-មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២.-សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។៩/-

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៣០...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស /៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាស ឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម /១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយ ច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦ /០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយ ចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១ : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១០០,០០០,០០០ រៀល (មួយរយលានរៀលគត់)ពីជំពូក៦១ (សេវាខាងក្រៅ)និងពីជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) មកជំពូក ៦០(ការទិញ) ជូនអាជ្ញាធរសវនកម្មជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញតំរូវការចំណាយជាក់ស្តែង របស់អាជ្ញាធរសវនកម្មជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឯកឧត្តមអគ្គសវនករនៃអាជ្ញាធរ សវនកម្មជាតិ ជាអ្នកទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១០រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត និងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងវិស័យអប់រំ សង្គមកិច្ច និងព្រះពុទ្ធសាសនា នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ឧកញ៉ា ម៉ក់ គឹមហុង

២-លោក ស្វាយ សុធី

៣-លោក ខ៊ូច អ៊ុយសេង

៤-លោក គង់ សំណាង

៥-លោក ឡឹក ផាន់ណា

៦-លោកស្រី ឌុំ ចាន់ធី

៧-លោកស្រី ឡុំ ឈីវឈុន

៨-ឧបាសិកា មាស ម៉េត

ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

-ព្រះតេជគុណ ខឹម សារាន

គ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

-ឧបាសក សេង ឈៀង

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តសុវណ្ណម៉ូលី (ហៅ វត្តគិរប្រាប) និងអនុវិទ្យាល័យ **ម៉ូនីរ៉ាន់-ហ៊ុនសែន** ស្ថិតក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ឯកឧត្តម ឡុញ វណ្ណៈ	ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ
២-ឯកឧត្តម សំ វណ្ណឌី	ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ
៣-លោក ប៉ែន សារ៉ាត់	ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ
៤-លោក ឈី ម៉ាន់នី	ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ
៥-លោក ម៉ម ឈាង	ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ
៦-លោក ចក់ ចន្ថា	ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ
៧-លោក មាស សឿន	ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក ម៉ាន់ ស៊ីវត្ថា	ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ
២-លោក ងាវ គឹមតិច	ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ
៣-លោក ឈឿន ណារ៉ី	ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ
៤-លោក ឡុក សេង	ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ
៥-លោក ឥន្ទ សារាន	ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ
៦-លោក អ៊ុច ចន្ធី	ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ
៧-លោក គឹម សោរិទ្ធ	ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ

គ_មេដាយសេរីវឌ្ឍនស្ថាបនាជាតិ :

១-លោក	**ចាន គាងឆាន់**	ទឹកប្រាក់ចំនួន	១.០០០ ដុល្លារ
២-លោក	**អ៊ាត ម៉ុនឃឿង**	ទឹកប្រាក់ចំនួន	១.០០០ ដុល្លារ
៣-លោក	**កើត ខួច**	ទឹកប្រាក់ចំនួន	១.០០០ ដុល្លារ
៤-លោក	**ជា ស្រេង**	ទឹកប្រាក់ចំនួន	១.០០០ ដុល្លារ
៥-លោក	**ស៊ិន ចុន្នី**	ទឹកប្រាក់ចំនួន	១.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និង អភិបាលខេត្តកំពង់ចាម ត្រូវ អនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៥៧៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការសំរួលភារកិច្ច និង តែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សម្រេច

មាត្រា ១ : ត្រូវបានសំរួលភារកិច្ចមន្ត្រីរាជការចំនួន ០២រូប ពីមុខតំណែងអភិបាលស្រុក អោយទៅទទួលភារកិច្ចថ្មីនៅក្នុងរចនាសម្ព័ន្ធសាលាខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :

១- លោក **ឈឹម ម៉ុននី** អភិបាលស្រុកថ្មពួក ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៤

២- លោក **គង់ ឈឿ** អភិបាលស្រុកសិរីសោភ័ណ ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ។

មាត្រា ២ : ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០២រូប មុខតំណែងអភិបាលស្រុក នៅខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :

១- លោក **ឌិន ប្រុសើដ្ឋ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ជាអភិបាលស្រុកថ្មពួក

២- លោក **អុំ រាត្រី** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ ជាអភិបាលស្រុកសិរីសោភ័ណ ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការសំរួល និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

សម្រេច

មាត្រា ១ : ត្រូវបានសំរួលភារកិច្ចមន្ត្រីរាជការចំនួន ០៣រូប ពីមុខតំណែងអភិបាលស្រុក នៅខេត្តសៀមរាប អោយទៅទទួលភារកិច្ចថ្មី នៅក្នុងរចនាសម្ព័ន្ធសាលាខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :

១- លោក ម៉ក់ សំនារ អភិបាលស្រុកសូទ្រនិគម ឋាននន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥

២- លោក ចៅ សែន អភិបាលស្រុកប្រាសាទបាគង ឋាននន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦

៣- លោក ឌេស ចំនួនគីរី អភិបាលស្រុកពួក ឋាននន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០៣រូប អោយទទួលមុខតំណែងជាអភិបាលស្រុក នៅខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :

១- លោក **ឌិត ជន** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ២ ជាអភិបាលស្រុកសូទ្រនិគម

២- លោក **តូ សំអាន** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៣ ជាអភិបាលស្រុកប្រាសាទបាគង

៣- លោក **ពេជ្រ សុខាល័យ** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៣ ជាអភិបាលស្រុកពួក ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៧៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបង្កើតនាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី ឡុ ខែម អត្តលេខ ០៧២១ ពីស្នងការរងស្នងការដ្ឋាននគរបាលខេត្តតាកែវ ទៅជាអនុប្រធាននាយកដ្ឋាននគរបាលការពារបេតិកភណ្ឌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំង និង ប្រគល់ភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្ត ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **គួច ពាច** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងយុត្តិធម៌ ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចមន្ត្រីរាជការ ក្រសួងយុត្តិធម៌ ដូចខាងក្រោម :

១_លោក **គី ខេមលីន** ឱ្យបំពេញមុខងារ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ ។

២_លោក **គីម សន្តិភាព** ឱ្យបំពេញមុខងារ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តនីការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ស ម្រេ ច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **សំហេង បុរស** អោយបំពេញមុខងារ ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ_កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ត្រូវបានបំពាក់ **មេដាយមាសការងារ** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោក **អ៊ុន សេង** អភិបាលរងស្រុកពួក ខេត្តសៀមរាប ដែលកន្លងមកលោកបានបូជាកំលាំងកាយ កំលាំងចិត្ត កំលាំងបញ្ញា ចូលរួមយ៉ាងសកម្មក្នុងការបំរើប្រទេសជាតិ ហើយបានទទួលមរណភាពដោយរោគាពាធ ។

មាត្រា ២ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៣៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ពាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់ប័ណ្ណស្ថាបនាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៥ រូប ដែលបានបរិច្ចាកថវិកាផ្ទាល់ខ្លួន ជួយកសាងអាគារសិក្សា ០១ ខ្នង មាន ០៥ បន្ទប់ ប្រឡាយ ០៥ ខ្សែ ប្រវែង ១៧.៩៥៦ ម៉ែត្រ ទំនប់ទឹក ០២ ខ្សែ ប្រវែង ២.០២៦ ម៉ែត្រ លូបង្ហូរទឹក ១១៣ កន្លែង អណ្តូងស្នប់ ៧៩ កន្លែង ស្រះទឹក ៦៥ ស្រះ និងទ្វារទឹក ០៤ កន្លែង ព្រមទាំងសមិទ្ធិផលនានាជាច្រើននៅក្នុងឃុំអន្សោង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោមនេះ :

១-លោកស្រី	**ឌូ ចន្ទ**	នាយិកាអង្គការប៉ាដិក	ថវិកាចំនួន ២៥.៩០០ ដុល្លារ
២-លោក	**ឌិន ឌូពាំ**	ប្រធានគ្រួតពិនិត្យហិរញ្ញវត្ថុ និង រដ្ឋបាល អង្គការប៉ាដិក	ថវិកាចំនួន ៤២.២៩៨ ដុល្លារ
៣-លោក	**កែវ សាន្ទ្យាន់**	មន្ត្រីគាំទ្រកម្មវិធីអង្គការប៉ាដិក	ថវិកាចំនួន ១១.៣៨០ដុល្លារ
៤- លោក	**ស្រី គុសល**	មន្ត្រីគាំទ្រកម្មវិធីអង្គការប៉ាដិក	ថវិកាចំនួន ១២.១០០ ដុល្លារ

៥-លោកស្រី ឡឹក ឡៅ	ប្រធានអង្គភាពគាំទ្រតំបន់ព្រៃវែង អង្គការប៉ាដិក	ថវិកាចំនួន ១៧,៣៧៨ដុល្លារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចមាត្រា ១ និងមាត្រា ២
ារ កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៣៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ ត្រូវបានបំពាក់ **មេដាយមាសការងារ** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោក **ញឹម ហុង** ក្រមការដើមខ្សែថ្នាក់លេខ ៧ អនុប្រធានក្រុមហិរញ្ញវត្ថុសាលាខេត្ត និងជាប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិត្រពាំងផ្លុង ខេត្តកំពង់ចាម ដែលកន្លងមកលោកបានបូជាកំលាំងកាយ កំលាំងចិត្ត កំលាំងបញ្ញា ចូលរួមយ៉ាងសកម្មក្នុងការបំរើប្រទេសជាតិ ហើយបានទទួលមរណភាពកាលពីថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧ ។

មាត្រា ២ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើត និងប្រើប្រាស់ប័ណ្ណស្ថាបនាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន ជូនសប្បុរសជនក្នុង និងក្រៅប្រទេសចំនួន ១៨ រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកាផ្ទាល់ខ្លួន ជួយកសាងសាលាបឋមសិក្សា ០២ ខ្នង មាន ១០ បន្ទប់ ផ្លូវក្រាលគ្រួសក្រហមប្រវែង ១,០៨០ ម៉ែត្រ កុដិ ០៣ ខ្នង សាលាឆាន់ ០១ ខ្នង ផ្ទះបាយ ០១ ខ្នង ផ្ទះឃាយជី ០៦ ខ្នង និងបង្គន់អនាម័យក្នុងវត្ត ០១ ខ្នង មាន ០៥ បន្ទប់ ព្រមទាំងសមិទ្ធិផលនានាជាច្រើន នៅវត្តចាន់ស៊ីសុទ្ធាវាសក្តបធំ ស្ថិតក្នុងឃុំនិមិត្ត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :

១-ព្រះវិភ័ទ្ទញាណ ព្រហ្ម ទៀន	គង់នៅសហរដ្ឋអាមេរិក	បច្ច័យចំនួន ១៩,៩០០ ដុល្លារ
២-ព្រះតេជគុណ ស៊ុខ ទុន្នី	ចៅអធិការវត្តចាន់ស៊ីសុទ្ធាវាសក្តបធំ	បច្ច័យចំនួន ១១,០០០ដុល្លារ
៣-លោក ស្កុត ខេនសុវណ្ណ	ខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៨៧,១៨០ ដុល្លារ
៤-លោកស្រី សុមារីយ៉ុនថាវី ខេនសុវណ្ណ	ខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៣០,១៨០ដុល្លារ

៥-លោក ប៊ុនធឿន ខាវធាំសឺត	ខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០,២០០ ដុល្លារ
៦-លោកស្រី ថេវ៉ែម ខាវធាំសឺត	ខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១០,១០០ ដុល្លារ
៧-លោក អាគុន ញ៉ឹម	ខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១២,០០០ ដុល្លារ
៨-លោក ម៉ៀង ចយ	ខ្មែររស់នៅប្រទេសកាណាដា	ថវិកាចំនួន ១០,១០០ ដុល្លារ
៩-លោក ឌួយ អ៊ីតថា	ខ្មែររស់នៅប្រទេសកាណាដា	ថវិកាចំនួន ១០,០៥០ ដុល្លារ
១០-លោក ឡៅ ឡាន់	ខ្មែររស់នៅប្រទេសបារាំង	ថវិកាចំនួន ១០,២៦០ ដុល្លារ
១១-លោក ឈឿន ចាន់ថាវី	ខ្មែររស់នៅប្រទេសបារាំង	ថវិកាចំនួន ១១,០០០ ដុល្លារ
១២-លោក ចរឹត ទាំងហាក់	ខ្មែររស់នៅប្រទេសនូវែលសេឡង់	ថវិកាចំនួន ១៣,០០០ ដុល្លារ
១៣-លោក សំអាត ចំនួ	ខ្មែររស់នៅប្រទេសនូវែលសេឡង់	ថវិកាចំនួន ១២,៥៨០ ដុល្លារ
១៤-ឧបាសក សោ ម៉ឹន និង ឧបាសិកា ស៊ុជា	ខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៩,៧៧០ ដុល្លារ
១៥-លោក អន និងលោកស្រី ទ៉ី	ខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៩,៧៧០ ដុល្លារ
១៦-លោក ឈឿម ឡាំ	នៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១០,៥៥០ ដុល្លារ
១៧-លោក ព្រហ្មី ចុច	នៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១០,៥០០ ដុល្លារ
១៨-លោក ឌូ ចំនួនទង	នៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១០,០៥០ ដុល្លារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ . ថ្ងៃទី [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
  ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ១៩៩៤ ស្តីពីការបង្កើត និង ប្រើប្រាស់ប័ណ្ណស្ថាបនាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ២៨ រូប ដែលបានយកអស់កំលាំងកាយចិត្ត និងបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងសមិទ្ធិផលនានា ជាច្រើននៅវិទ្យាល័យមង្គលបូរី ក្នុងស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :

ក- **មេដាយមាសស្ថាបនាជាតិ**

១-	ឯកឧត្តម អន ស៊ំ	ថវិការចំនួន ១០.០០០ ដុល្លាអាមេរិក
២-	លោក ម៉ុក សារុយ	ថវិការចំនួន ១០.០០០ ដុល្លាអាមេរិក
៣-	លោក សុខ សារេត	ថវិការចំនួន ១០.០០០ ដុល្លាអាមេរិក
៤-	លោក សរ ចំរុង	ថវិការចំនួន ១០.០០០ ដុល្លាអាមេរិក
៥-	លោក គោ ស៊ុំសារឿន	ថវិការចំនួន ១០.០០០ ដុល្លាអាមេរិក
៦-	លោក ចៅហ្វាយ ឆ្នុយ	ថវិការចំនួន ១០.០០០ ដុល្លាអាមេរិក
៧-	លោក គី គៀនហួត	ថវិការចំនួន ១០.០០០ ដុល្លាអាមេរិក
៨-	លោក ញ៉ឹម ហ៊ីរ	ថវិការចំនួន ៦.០០០ ដុល្លាអាមេរិក
៩-	លោកឧកញ៉ា ចាន់ ស៊ីផារតនៈ	ថវិការចំនួន ៥.០០០ ដុល្លាអាមេរិក
១០-	ឯកឧត្តម ម៉ុន សេថ	ថវិការចំនួន ៥.០០០ ដុល្លាអាមេរិក
១១-	ឯកឧត្តម សុខ ឆាត	ថវិការចំនួន ៥.០០០ ដុល្លាអាមេរិក
១២-	លោក គួន់ ដារា	ថវិការចំនួន ៥.០០០ ដុល្លាអាមេរិក

ខ- មេដាយប្រាក់ស្ថាបនាជាតិ

១-	លោក	ឆូច គិមឆេង	ថវិកាចំនួន	២.០០០ ដុល្លាអាមេរិក
២-	លោក	ឆូ ជាង	ថវិកាចំនួន	២.០០០ ដុល្លាអាមេរិក
៣-	លោក	លឹម លុយ	ថវិកាចំនួន	១.២០០ ដុល្លាអាមេរិក
៤-	ឧបាសក	ឡេង គិមហេង	ថវិកាចំនួន	១.២០០ ដុល្លាអាមេរិក
៥-	លោក	គាត លីអុង	ថវិកាចំនួន	១.២០០ ដុល្លាអាមេរិក
៦-	លោក	ចៅ តាង	ថវិកាចំនួន	១.២០០ ដុល្លាអាមេរិក
៧-	លោក	ប៊ុន ហោ	ថវិកាចំនួន	១.០០០ ដុល្លាអាមេរិក
៨-	លោក	អ៊ូ ឡុងឌី	ថវិកាចំនួន	១.០០០ ដុល្លាអាមេរិក
៩-	លោក	នុំ ឆាន់	ថវិកាចំនួន	១.០០០ ដុល្លាអាមេរិក
១០-	លោក	ពុធ ឈាង	ថវិកាចំនួន	១.០០០ ដុល្លាអាមេរិក

គ- មេដាយសំរិទ្ធស្ថាបនាជាតិ

១-	លោក	អ៊ី ឡុង	ថវិកាចំនួន	១.០០០ ដុល្លាអាមេរិក
២-	លោក	ឈឿង ឡី	ថវិកាចំនួន	១.០០០ ដុល្លាអាមេរិក
៣-	លោក	លុយ សម្បត្តិ	ថវិកាចំនួន	១.០០០ ដុល្លាអាមេរិក
៤-	លោកស្រី ឈឿម	ឡុម	ថវិកាចំនួន	១.០០០ ដុល្លាអាមេរិក
៥-	លោក	មេ ឡិគីម	ថវិកាចំនួន	១.០០០ ដុល្លាអាមេរិក
៦-	លោក	សំ ប្រសិទ្ធិ	ថវិកាចំនួន	១.០០០ ដុល្លាអាមេរិក

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- [illegible]វាំងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤ ស.សរ

សេចក្តីសម្រេច
ស្តីពីការចាត់តាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០២/១១៣ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់កាកបាទក្រហមកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៦១៧ អនក្រ.តត ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពីការទទួលស្គាល់គណៈកម្មាធិការកណ្តាល អាណត្តិទី ៤ សមាជិកបំរុង ឥស្សរជន និង អគ្គលេខាធិការ អគ្គលេខាធិការរងកាកបាទក្រហមកម្ពុជា
- យោងតាមការចាំបាច់

សម្រេច

ប្រការ ១ : ត្រូវបានចាត់តាំងលោកជំទាវ ម៉ែន នារីសោភ័គ នាយិការងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ឱ្យទទួលបន្ទុកការងារកាកបាទក្រហមកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុង ប្រធានកាកបាទក្រហមកម្ពុជា ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥ សសរ

សេចក្តីសម្រេច

ស្តីពី

ការតែងតាំងសមាសភាពក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈ នៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០២ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខានៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩២

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣២ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការអន្តរជាតិខាងការងារលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៦ / ០០៤ ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញសេចក្តីសម្រេចលេខ ១៣ សសរ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិដើម្បីអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

ស ម្រេ ច

ប្រការ ១.-

ត្រូវបានតែងតាំងសមាសភាពក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ (គ.អ.ល.ជ) ដូចតទៅ :

១-	លោកជំទាវ **យូ អៃយ**	រដ្ឋលេខាធិការក្រសួងកិច្ចការនារី	ប្រធាន
២-	ឯកឧត្តម **នូ តឿង**	អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៣-	ឯកឧត្តម **នឹម ចំន្ទតារា**	អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
៤-	ឯកឧត្តម **ម៉ុល ម៉េងហួរ**	អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	អនុប្រធាន
៥-	ឯកឧត្តម **អ៊ិត រ៉ាឌី**	អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌	អនុប្រធាន
៦-	ឯកឧត្តម **ទឹម ទិសិដ្ឋ**	សមាជិកក្រុមស្រង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធាននាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក

៧- ឯកឧត្តម **ឈី សៀមឡាក់**	អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៨- លោក **ឌួច សាម៉ុន**	អគ្គនាយករងបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
៩- លោកស្រី **ញឹម ម៉ាន់ចំនួតន**	អគ្គាធិការរង ក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១០- លោក **ហោ សារុន**	អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ក្រសួងទេសចរណ៍	សមាជិក
១១- លោកស្រី **ហេង ស៊ីថុន**	អគ្គនាយករងអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី	សមាជិកអចិន្ត្រៃយ៍
១២- លោក **យូ ម៉ាសិទ្ធ**	អគ្គលេខាធិការរង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី	សមាជិក
១៣- លោកស្រី **ខា ផល្លីន**	អគ្គនាយករងវិទ្យុជាតិកម្ពុជា ក្រសួងព័ត៌មាន	សមាជិក
១៤- លោកឧត្តមសេនីយ៍ត្រី **អ៊ុក សារ៉ាន់**	នាយសេនាធិការរង កងរាជអាវុធហត្ថ ក្រសួងការពារជាតិ	សមាជិក
១៥- លោកស្រីឧត្តមសេនីយ៍ត្រី **អ៊ុន សុគន្ធា**	ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ	សមាជិក
១៦- លោក **ទេង ហៀង**	ប្រធាននាយកដ្ឋានការងារកុមារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
១៧- លោក **គីម សុវណ្ណា**	អនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
១៨- លោកស្រី **ចំន្ទ ហារ៉ាន់ចន្ទី**	អគ្គលេខាធិការរង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ	សមាជិក

ប្រការ ២.-

សមាជិក សមាជិកា នៃ **ក.អ.ល.ជ** មានភារកិច្ចអនុវត្តការងារទៅតាមការតម្រង់ទិសដៅនៃសេចក្តីសម្រេចលេខ ១៣ សសរ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតក្រុមការងារ ថ្នាក់ជាតិដើម្បីអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ។

ប្រការ ៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *រាជកិច្ច ✓*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៦៥ សហវ

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០០៧

ប្រកាស

ស្តីពី

ការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក.ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែ ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០៣ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញក្រឹត្យលេខ៥៧ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញនាំចូល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលបានប្រកាស ឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ
- បានឃើញពិធីសារស្តីពីការអនុវត្តនាមវលី នៃតារាងពន្ធគយស៊ីចង្វាក់គ្នារបស់អាស៊ាន ដែលចុះហត្ថលេខា ដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ នៅទីក្រុងម៉ានិល ប្រទេសហ្វីលីពីន
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធ និងអាករគយលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេស លើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : ដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០០៧ ដូចមានភ្ជាប់ជាមួយនេះ ដែលបានរៀបចំដោយអនុលោមតាមប្រព័ន្ធស៊ីចង្វាក់ នៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ និងស្របទៅតាមតារាងពន្ធគយ នៃប្រព័ន្ធស៊ីចង្វាក់របស់អាស៊ាន (AHTN 2007) ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៧ តទៅ ។

ប្រការ ២ : រាល់មុខទំនិញនាំចេញ នាំចូលត្រូវជាប់ពន្ធនាំចូល អាករពិសេស អាករលើតម្លៃបន្ថែម និងអាករនាំចេញ ដូចមានចែងលំអិតក្នុងតារាងពន្ធគយនេះ ។

ប្រការ ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ ខាងមុខនេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត់ ឈន់

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ខេត្តក្រុង "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្ម
- ទីចាត់ការគយ និងរដ្ឋាករ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ខ មកពីរាជកិច្ចលេខ ៤៩,៥០,៥១,៥២

កាកសំណល់ពីឧស្សាហកម្ម ម្ហូបអាហារ ចំណីសំរាប់សត្វ

Residues and waste from the food industries; prepared animal fodder

កំណត់សំគាល់

Notes.

1.- ទីតាំងលេខ ២៣.០៩ រួមមានផលិតផលដែលប្រើជាចំណីសត្វ ហើយមិនមានក្នុងជំពូកណាមួយនៃតារាងពន្ធនេះ ។ ចំណីសត្វនេះទទួលបានដោយសារការកែច្នៃវត្ថុធាតុរបស់សត្វ ឬបន្លែឲ្យដល់កំរិតមួយ ដែលបាត់បង់លក្ខណៈនៃរូបធាតុដើម នៃវត្ថុធាតុនោះ ។ ហើយនៅសល់តែកាកសំណល់បន្លែ និងផលិតផលបានពីការកែច្នៃនោះ ។

Heading No. 23.09 includes products of a kind used in animal feeding, not elsewhere specified or included, obtained by processing vegetable or animal materials to such an extent that they have lost the essential characteristics of the original material, other than vegetable waste, vegetable residues and by-products of such processing.

កំណត់សំគាល់អនុមុខទំនិញ

Subheading Note.

1.- ចំពោះទីតាំងរង ២៣០៦៤១ ពាក្យ "Low erucic acid rape or colza seeds" មានន័យជាគ្រាប់ដែលបានពន្យល់នៅទីតាំងរងនៃកំណត់សំគាល់ ១ ក្នុងជំពូក១២ ។

For the purposes of subheading 2306.41, the expression "low erucic acid rape or colza seeds" means seeds as defined in Subheading Note 1 to Chapter 12.

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
23.01		ម្សៅ ម្សៅគីន និងគ្រាប់ ឬដុំនៃសាច់ ឬគ្រឿងក្នុងសាច់នៃត្រី ឬនៃសត្វសមុទ្រ (ក្តាម បង្កង បង្គា...) សិប្បសត្វ ឬក្រុមសត្វឥតឆ្អឹងខ្នងដែលរស់ក្នុងទឹកដទៃទៀតដែលមនុស្សមិនអាចបរិភោគបាន ស្បែកអាំងក្រៀម ។	**Flours, meals and pellets, of meat or meat offal , of fish or of crustaceans, molluscs or other aquatic invertebrates, unfit for human consumption; greaves.**						
	2301.10.00	- ម្សៅ ម្សៅគីន និង គ្រាប់ឬដុំសាច់ ឬគ្រឿងក្នុងសាច់ ស្បែកអាំងក្រៀម	- Flours, meals and pellets, of meat or meat offal , greaves	kg	7	0	10	0	
	2301.20.00	- ម្សៅ ម្សៅគីន និងគ្រាប់ ឬដុំសាច់នៃត្រី ឬ នៃសត្វសមុទ្រ (ក្តាម បង្កង បង្គា) សិប្បសត្វ ឬសត្វឥតឆ្អឹងខ្នងរស់ក្នុងទឹកដទៃទៀត	- Flours, meals and pellets, of fish or of crustaceans, molluscs or other aquatic invertebrates	kg	7	0	10	0	

23.02		កន្ទក់ កំទេចកំទីស្រួយៗ និងកាកសំណល់ដទៃទៀត ទោះជាមានសភាពជាកំទេចកំទីកដោយដែលបានមកដោយតាមរយៈការរែង កិន ឬតាមរយៈការយកគ្រាប់ធុញ្ញជាតិ ឬរុក្ខជាតិឡេហ្គូមមកកែច្នៃ ។	**Bran, sharps and other residues, whether or not in the form of pellets, derived from the sifting, milling or other working of cereals or of leguminous plants.**						
	2302.10.00	- នៃពោត	- Of maize (corn)	kg	7	0	10	0	
	2302.30.00	- នៃស្រូវសាលី	- Of wheat	kg	7	0	10	0	
	2302.40	- នៃគ្រាប់ធុញ្ញជាតិដទៃទៀត :	- Of other cereals:						
	2302.40.10	- -ពីស្រូវ	- - Of rice	kg	7	0	10	0	
	2302.40.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
	2302.50.00	- នៃរុក្ខជាតិឡេហ្គូម	- Of leguminous plants	kg	7	0	10	0	
23.03		កាកសំណល់បានមកពីការផលិតម្សៅស្តាច់ និងកាកសំណល់ស្រដៀងគ្នា នេះ ឬសរុក្ខជាតិប៊ីត កំទេចស្ករ អំពៅ ឬស្ករុក្ខជាតិប៊ីត និងកាកសំណល់បានមកពីការផលិតស្ករ ការផ្សងឬចិតកករ និងកាកសំណល់ទោះបីមានទំរង់ជាគ្រាប់ក៏ដោយ ។	**Residues of starch manufacture and similar residues, beet-pulp, bagasse and other waste of sugar manufacture, brewing or distilling dregs and waste, whether or not in the form of pellets.**						
	2303.10	- កាកសំណល់បានមកពីការផលិតម្សៅស្តាច់និងកាកសំណល់ស្រដៀងគ្នានេះ	- Residues of starch manufacture and similar residues:						
	2303.10.10	- - ពីដំឡូង ឬ ម្សៅសាគូ	- - Of manioc (cassava)or sago	kg	7	0	10	0	
	2303.10.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
	2303.20.00	- ឬសរុក្ខជាតិប៊ីត កំទេចស្ករអំពៅ ឬស្ករុក្ខជាតិប៊ីត និងកាកសំណល់បានមកពីការផលិតស្ករផ្សេងទៀត	- beet-pulp, bagasse and other waste of sugar manufacture	kg	7	0	10	0	
	2303.30.00	- ការផ្សង ឬចិតកករ និងកាកសំណល់	- brewing or distilling dregs and waste	kg	7	0	10	0	

23.04	2304.00.00	កាកសំណល់ពីគ្រាប់ផ្សេងៗ និងកាកសំណល់រឹងផ្សេងទៀត ទោះបីកិនឬធ្វើជារាងមូលដែលបានមកពីការចំរាញ់ចេញពីប្រេងសណ្តែកសៀង ។	Oil-cake and other solid residues,whether or not ground or in the form of pellets, resulting from the extraction of soya - bean oil.	kg	7	0	10	0	
23.05	2305.00.00	កាកសំណល់ពីគ្រាប់ផ្សេងៗ និងកាកសំណល់រឹងផ្សេងទៀតទោះបីកិន ឬធ្វើជារាងមូល ដែលបានមកពីការចំរាញ់ចេញពីប្រេងសណ្តែកដី ។	Oil-cake and other solid residues,whether or not ground or in the form of pellets, resulting from the extraction of ground-nut oil.	kg	7	0	10	0	
23.06		កាកសំណល់ពីគ្រាប់ផ្សេងៗ និងកាកសំណល់រឹងផ្សេងទៀត ទោះបីកិនឬធ្វើជារាងមូលពីការចំរាញ់យកខ្លាញ់ប្រេងរុក្ខជាតិក្រៅ ពីកាកសំណល់នៅក្នុងទីតាំងលេខ ២៣.០៤ ឬ ២៣.០៥ ។	**Oil-cake and other solid residues, whether or not ground or in the form of pellets, resulting from the extraction of vegetable fats or oils, other than those of heading No. 23.04 or 23.05.**						
	2306.10.00	- នៃគ្រាប់កប្បាស	- Of cotton seeds	kg	7	0	10	0	
	2306.20.00	- នៃគ្រាប់ល្ង	- Of linseed	kg	7	0	10	0	
	2306.30.00	- នៃគ្រាប់ផ្កាឈូករ័ត្ន	- Of sunflower seeds	kg	7	0	10	0	
		- នៃគ្រាប់របស់រុក្ខជាតិរេប :	- Of rape or colza seeds:						
	2306.41.00	- - គ្រាប់រុក្ខជាតិរេប ឬ កូហ្សា ដែលមានអាស៊ីត អេរូស៊ិកទាប	- - Of low erucic acid rape or colza seeds	kg	7	0	10	0	
	2306.49.00	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
	2306.50.00	- នៃគ្រាប់នៃផ្លែដូងឬសាច់ដូងស្ងួត	- Of coconut or copra	kg	7	0	10	0	
	2306.60.00	- នៃគ្រាប់ត្នោត	- Of palm nuts or kernels	kg	7	0	10	0	
	2306.90	- ផ្សេងទៀត :	- Other :						
	2306.90.20	- - ពីពោត ពោតក្រហម	- - Of maize (corn) germ	kg	7	0	10	0	
	2306.90.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
23.07	2307.00.00	កាកស្រាទំពាំងបាយជូរ និងកករនៃធុងស្រា	Wine lees; argol.	kg	7	0	10	0	

23.08	2308.00.00	វត្ថុធាតុរុក្ខជាតិ និងកាកសំណល់រុក្ខជាតិទោះបីផ្តុំជាគ្រាប់មូលក៏ដោយ ក្នុងប្រភេទដែលប្រើសំរាប់ធ្វើចំណីសត្វដែលពុំមានកំណត់ឬបញ្ជាក់នៅទីតាំងផ្សេងទៀត ។	**Vegetable materials and vegetable waste, vegetable residues and by-products, whether or not in the form of pellets, of a kind used in animal feeding,not elsewhere specified or included.**	kg	7	0	10	0	
23.09		ប្រភេទចំណីអាហារសំរាប់ចិញ្ចឹមសត្វ	**Preparations of a kind used in animal feeding.**						
	2309.10	- ចំណីសំរាប់ឆ្កែ ឬឆ្មា ដែលវេចខ្ចប់សំរាប់លក់រាយ	- Dog and cat food ,put up for retail sale :						
	2309.10.10	- - មានជាតិសាច់	- - Containing meat	kg	35	0	10	0	
	2309.10.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
	2309.90	- ផ្សេងទៀត :	- Other :						
		- - ចំណីរួចស្រេច :	- - Completed feeds:						
	2309.90.11	- - - សំរាប់បសុបក្សី	- - - for poultry	kg	7	0	10	0	
	2309.90.12	- - - សំរាប់សត្វជ្រូក	- - - for swine	kg	7	0	10	0	
	2309.90.13	- - - សំរាប់ព្រោន	- - - Prawn feed	kg	7	0	10	0	
	2309.90.19	- - - ផ្សេងទៀត	- - - Other	kg	7	0	10	0	
	2309.90.20	- - ចំណីលាយចំរុះគ្នា អ្វីផ្សេងទៀតប្រើជាចំណីអាហារ	- - Premixes,feed supplements and feed additives	kg	7	0	10	0	
	2309.90.30	- - ផ្សេងទៀត មានជាតិសាច់	- - Other, containing meat	kg	7	0	10	0	
	2309.90.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	

ជំពូកទី ២៤ / Chapter 24

ថ្នាំជក់ និងផលិតផលពីថ្នាំជក់ / Tobacco and manufactured tobacco substitutes

កំណត់សំគាល់

Note.

ជំពូកនេះមិនរាប់បញ្ចូលនូវបារីឱសថ (ជំពូក ៣០) ។ This chapter does not cover medicinal cigarettes (chapter 30)

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%) Imp. CD	ST	VAT	Exp. ET	Reference
24.01		ថ្នាំជក់ឆៅ ឬ ជាវត្ថុធាតុដើមសំណល់ថ្នាំជក់	**Unmanufactured tobacco; tobacco refuse.**						
	2401.10	- ថ្នាំជក់ មិនយកទង ឬ បេះយកទងចេញ :	- Tobacco, not stemmed/stripped :						
	2401.10.10	- - ថ្នាំជក់វើជីនីញ៉ា បំពង់ក្បាលកំដៅដោយបានយូរ	- - Virginia type, flue cured	kg	15	0	10	0	
	2401.10.20	- - ថ្នាំជក់វើជីនីញ៉ា មិនដាក់ក្នុងបំពង់ក្បាលកំដៅដោយបានយូរ	- - Virginia type, not flue cured	kg	15	0	10	0	
	2401.10.30	- - ផ្សេងទៀតបំពង់ក្បាលកំដៅដោយបានយូរ	- - Other, flue cured	kg	15	0	10	0	
	2401.10.90	- - ផ្សេងទៀតមិនដាក់ក្នុងបំពង់ក្បាលកំដៅបានយូរ	- - Other, not flue cured	kg	15	0	10	0	
	2401.20	- ថ្នាំជក់ ដែលបានយកទង ឬបេះយកទងចេញទាំងស្រុង ឬតែមួយផ្នែក :	- Tobacco, partly or wholly stemmed/stripped :						
	2401.20.10	- - ប្រភេទវើជីនីញ៉ា ដាក់ក្នុងបំពង់ក្បាលកំដៅដោយបានយូរ	- - Virginia type, flue cured	kg	15	0	10	0	
	2401.20.20	- - ប្រភេទវើជីនីញ៉ា មិនដាក់ក្នុងបំពង់ក្បាលកំដៅដោយបានយូរ	- - Virginia type, not flue cured	kg	15	0	10	0	
	2401.20.30	- - ប្រភេទ Oriental	- - Oriental type	kg	15	0	10	0	
	2401.20.40	- - ប្រភេទ Burley	- - Burley type	kg	15	0	10	0	
	2401.20.50	- - ផ្សេងទៀត ដាក់ក្នុងបំពង់ក្បាលកំដៅដោយបានយូរ	- - Other,flue-cured	kg	15	0	10	0	
	2401.20.90	- - ផ្សេងទៀត ដាក់ក្នុងបំពង់ក្បាលកំដៅដោយបានយូរ	- - Other,not flue-cured	kg	15	0	10	0	
	2401.30	- កាកសំណល់ថ្នាំជក់	- Tobacco refuse						
	2401.30.10	- - ទងថ្នាំជក់	- - Tobacco stems	kg	15	0	10	0	
	2401.30.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
24.02		បារីស៊ីហ្គា រួមទាំងស៊ីហ្គាចុងកាត់ ស៊ីហ្គាតូចៗ និងបារីផលិតពីថ្នាំជក់ ឬពីថ្នាំជក់សិប្បនិម្មិត ។	**Cigars, cheroots, cigarillos and cigarettes, of tobacco or of tobacco substitutes.**						
	2402.10.00	- បារីស៊ីហ្គា រួមទាំងស៊ីហ្គាចុងកាត់ ស៊ីហ្គាតូចៗផលិតពីថ្នាំជក់	- Cigars, cheroots and cigarillos, containing tobacco	kg	35	25	10	0	

	2402.20	- បារីផលិតពីថ្នាំជក់ :	- Cigarettes containing tobacco :						
	2402.20.10	- - បារីប៊ីឌី របស់ឥណ្ឌា	- - Beedies	kg	7	10	10	0	
	2402.20.90	- - ផ្សេងទៀត	- - Other	kg	7	10	10	0	
	2402.90	- ផ្សេងទៀត :	- Other :						
	2402.90.10	- - បារីស៊ីហ្គា ស៊ីហ្គាចុងកាត់ និងស៊ីហ្គាតូចៗផលិត ពីថ្នាំជក់សិប្បនិម្មិត	- - Cigars, cheroots and cigarillos, containing tobacco substitutes	kg	35	25	10	0	
	2402.90.20	- - បារី ផលិតពីថ្នាំជក់សិប្បនិម្មិត	- - Cigarettes containing tobacco substitutes	kg	35	25	10	0	
24.03		ថ្នាំជក់ផ្សេងទៀត វត្ថុពីថ្នាំជក់ដែលផលិតរួច ថ្នាំជក់លាយស្មើសាច់ ឬផ្គុំឡើងវិញ "ជាតិចំរាញ់ និងទឹកថ្នាំជក់" ។	**Other manufactured tobacco and manufactured tobacco substitutes; "homogenised " or "reconstituted" tobacco; tobacco extracts and essences.**						
	2403.10	- បារីសំរាប់ជក់ ទោះផលិត ឬមិនផលិតពីថ្នាំជក់សិប្បនិម្មិតនៅក្នុងសមាមាត្រណាមួយក៏ដោយ :	- Smoking tobacco, whether or not containing tobacco substitutes in any proportion :						
		- - ខ្ចប់ជាកញ្ចប់សំរាប់ការលក់រាយ	- - Packed for retail sale:						
	2403.10.11	- - - ថ្នាំជក់លាយបញ្ចូលគ្នា	- - - Blended tobacco	kg	35	0	10	0	
	2403.10.19	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
		- - ថ្នាំជក់ផ្សេងទៀត ដែលគេផលិតឡើងសំរាប់ការធ្វើបារី :	- - Other manufactured tobacco for cigarette making:						
	2403.10.21	- - - ថ្នាំជក់លាយបញ្ចូលគ្នា	- - - Blended tobacco	kg	35	0	10	0	
	2403.10.29	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
	2403.10.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
		- ផ្សេងទៀត :	- Other :						
	2403.91.00	- - ថ្នាំជក់ ស្មើសាច់ ឬ ផ្គុំឡើងវិញ	- - "Homogenised" or "reconstituted" tobacco	kg	35	0	10	0	
	2403.99	- - ផ្សេងទៀត :	- - Other :						
	2403.99.10	- - - សារធាតុចំរាញ់ចេញពីថ្នាំជក់ និងទឹកថ្នាំជក់	- - - Tobacco extracts and essences	kg	35	0	10	0	
	2403.99.30	- - - វត្ថុចេញពីថ្នាំជក់ដែលគេផលិត	- - - Manufactured tobacco substitutes	kg	35	0	10	0	

	2403.99.40	- - - ថ្នាំជក់សំរាប់ហឹត	- - - Snuff	kg	35	0	10	0	
	2403.99.50	- - - ថ្នាំជក់មិនប្រើសំរាប់ជក់ រួមទាំងថ្នាំជក់សំរាប់បៀម	- - - Smokeless tobacco, including chewing and sucking tobacco	kg	35	0	10	0	
	2403.99.60	- - - ថ្នាំអាំងហ៊ុន	- - - Ang Hoon	kg	35	0	10	0	
	2403.99.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	

ផ្នែកទី V

ផលិតផលជាតិរ៉ែ

Section V

MINERAL PRODUCTS

ជំពូកទី ២៥

អំបិល ស្ពាន់ធ័រ ដី និងថ្មសិលា ម្នាងសិលា និងស៊ីម៉ង់ត៍

Chapter 25

Salt, sulphur, earths and stone; plastering materials, lime and cement

កំណត់សំគាល់

Notes.

1.- លើកលែងតែករណីផ្ទុយពីនេះ និងស្ថិតនៅក្នុងលក្ខខណ្ឌកំណត់សំគាល់លេខ ៤ ខាងក្រោមអាចរាប់បញ្ចូលទៅក្នុងជំពូកនេះ បានតែចំពោះផលិតផលដែលនៅឆៅឬក៏ផលិតផលលាង (ទោះបីលាងនឹងសារធាតុគីមីដែលកំចាត់ភាពមិនសុទ្ធដោយគ្មានផ្លាស់ប្តូរទ្រង់ទ្រាយនៃផលិតផល) បំបែកជាដុំ កិនល្អិតកិនឱ្យហ្មត់ដោយទឹក ច្រោះរើសរែងយកភាពសុទ្ធដោយបណ្តែតទឹកញែកយកជាតិរ៉ែដោយប្រើដែកឆក់និងវិធីយន្តកម្ម ឬរូបកម្មផ្សេងទៀត "លើកលែងតែការធ្វើឱ្យចេញជាគ្រាប់ស្លត" ប៉ុន្តែពុំមែនផលិតផល ដែលអាំងឬលីងកំឡោច ដែលបានមកពីល្បាយឬក៏ដែលបានទទួលនូវការកែច្នៃក៏តែខ្ពស់ជាងការកែច្នៃដែលបានចង្អុលក្នុងទីតាំងនីមួយៗ ។

Except where their context or Note 4 to this Chapter otherwise requires, the headings of this Chapter cover only products which are in the crude state or which have been washed (even with chemical substances eliminating the impurities without changing the structure of the product), crushed, ground, powdered, levigated, sifted, screened, concentrated by flotation, magnetic separation or other mechanical or physical processes (except crystallisation), but not products which have been roasted, calcined, obtained by mixing or subjected to processing beyond that mentioned in each heading.

ផលិតផលក្នុងជំពូកនេះ អាចបន្ថែមនូវសារធាតុបងិបក្ខនឹងធូលី កុំឱ្យតែការបន្ថែមនេះប្រែក្លាយផលិតផលយកទៅបំរើការពិសេសក្រៅពីបំរើការទូទៅ ។

The products of this Chapter may contain an added anti-dusting agent, provided that such addition does not render the product particularly suitable for specific use rather than for general use.

2.- ជំពូកនេះមិនរាប់បញ្ចូលនូវ :

This chapter does not cover:

(a) ស្ពាន់ធ័រ [Le souffre sublimé, le souffre précipité et le souffre colloidal] ទីតាំងលេខ ២៨.០២ ។

Sublimed sulphur, precipitated sulphur or colloidal sulphur (heading No. 28.02);

(b) ដីមានពណ៌ដែលមានទម្ងន់ ៧០ % ឬមានដែមនូវជាតិដែកដូ Fe_2O_3 ទីតាំងលេខ ២៨.២១

Earth colours containing 70 % or more by weight of combined iron evaluated as Fe_2O_3 (heading No. 28.21);

(c) ឱសថ និងបណ្តាផលិតផលក្នុងជំពូក ៣០

Medicaments or other products of Chapter 30;

(d) ផលិតផលសុគន្ធជាតិ ឬសំរាប់សំអាងកាយ និងផលិតផលគ្រឿងក្រអូប ជំពូក៣៣

Perfumery, cosmetic or toilet preparations (Chapter 33);

	(e)	ថ្មក្រាល ថ្មចិញ្ចើមផ្លូវ និងផ្ទាំងថ្ម សំរាប់ក្រាល (ទីតាំងលេខ ៦៨.០១) ថ្មតូច សំរាប់ ធ្វើគំនូរវិចិត្រដែលកើតពីការផ្សំបន្តូចៗ ឬវត្ថុប្រហាក់ប្រហែលគ្នា(ទីតាំងលេខ ៦៨.០២) ។ ក្តារឈ្នួនសំរាប់ប្រក់ដំបូល ឬសំរាប់បាំងពីក្រៅ ឬថ្មក្រាលជាស្រទាប់សំរាប់អគារ (ទីតាំងលេខ ៦៨.០៣) ។	Setts, curbstones or flagstones (heading No. 68.01); mosaic cubes or the like (heading No. 68.02); roofing, facing or damp course slates (heading No. 68.03);
	(f)	ត្បូងថ្មទីតាំងលេខ " ៧១.០២ ឬ ៧១.០៣ "	Precious or semi-precious stones (heading No. 71.02 or 71.03);
	(g)	គ្រាប់ដែលនឹងកើតជាអំបិល (ក្រៅពីឧបករណ៍អុបទិច) មានទំងន់នីមួយៗលើសពី២.៥ក្រាម ធ្វើពីសូដ្យូមក្លរ ឬពីម៉ាញ៉េស្យូមអុកស៊ីត (ទីតាំងលេខ ៣៨.២៤) ។ ឧបករណ៍អុបទិកធ្វើពីសូដ្យូមក្លរ ឬពីម៉ាញ៉េស្យូមអុកស៊ីត ទីតាំងលេខ ៩០.០១) ។	Cultured crystals (other than optical elements) weighing not less than 2.5 g each, of sodium chloride or of magnesium oxide, of heading No. 38.24; optical elements of sodium chloride or of magnesium oxide (heading No. 90.01);
	(h)	ដីសសំរាប់ប៊ីយ៉ា " ទីតាំងលេខ ៩៥.០៤ " (Les craies de billards)	Billiard chalks (heading No. 95.04); or
	(ij)	ដីសសំរាប់សរសេរ និងសំរាប់គូរ និងដីសសំរាប់ជាងកាត់ដេរ (ទីតាំងលេខ ៩៦.០៩)	Writing or drawing chalks or tailors' chalks (heading No. 96.09).
3.-		រាល់ផលិតផលដែលអាចចាត់ចូលក្នុងទីតាំងលេខ ២៥.១៧ ផង និងក៏អាចចំណាត់ក្នុងទីតាំងផ្សេងទៀតផងនឹងត្រូវបានចំណាត់ក្នុងទីតាំងលេខ ២៥.១៧ ។	Any products classifiable in heading No. 25.17 and any other heading of the Chapter are to be classified in heading No. 25.17.
4.-		ទីតាំងលេខ ២៥.៣០ រាប់បញ្ចូលផងដែរនូវ La vermiculite,la verti culite et le chlorite non expansé ដីមានពណ៌ទោះជាល្បាយក៏ដោយ ។ ពពួកដែកអុកស៊ីតដែលមានជាតិមីកាធម្មជាតិ ពពុះសមុទ្រធម្មជាតិ ទោះជាមានពងដុំរលោង ក៏ដោយ ។ ជ័រធម្មជាតិក្នុងសមុទ្រ ពពុះសមុទ្រ និងជ័រសមុទ្រដទៃទៀតដែលបានកែច្នៃហើយជារៀងផ្សេងៗ ។ ថ្មខ្មៅអណ្តើក Strontiantte ទោះជាដុតឬមិនដុតក៏ដោយលើកលែងតែ Oxyde de strontium, អំបែងកែវ ឬអំបែងសេរ៉ាមិក ។	Heading No. 25.30 applies, inter alia, to : vermiculite, perlite and chlorites, unexpanded; earth colours, whether or not calcined or mixed together; natural micaceous iron oxides; meerschaum (whether or not in polished pieces); amber; agglomerated meerschaum and agglomerated amber, in plates, rods, sticks or similar forms, not worked after moulding; jet; strontianite (whether or not calcined), other than strontium oxide; broken pottery,brick or concrete.

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Imp.			Exp.	Referen
					CD	ST	VAT	ET	
25.01		អំបិល (រាប់បញ្ចូលទាំងអំបិលបរិភោគ និងអំបិលបំប្លែង) និងសូដ្យូមក្លរួបរិសុទ្ធ ទោះបីលាយទឹកសមុទ្រ ។	**Salt (including table salt and denatured salt) and pure sodium chloride, whether or not in aqueous solution or containing added anti-caking or free-flowing agents; sea water.**						
	2501.00.10	- អំបិលសំរាប់បរិភោគ	- Table salt	kg	35	0	10	0	
		- អំបិលដែលមានសូដ្យូមក្លរួយ៉ាងតិច ៩៤.៧ %។ ដោយគិតលើមូលដ្ឋានស្ងួត :	- Other salt containing at least 94.7%of sodium chloride calculated on a dry basis:						
	2501.00.41	- - ក្នុងកញ្ចប់មានទម្ងន់តិចជាង ៤៥ គក្រ	- - In package of a net weight of less than 45 kg	kg	15	0	10	0	
	2501.00.49	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
	2501.00.50	- - ទឹកសមុទ្រ	- - Sea water	kg	15	0	10	0	
25.02	2502.00.00	ពៀរីត "ជាតិលាយស្ពាន់ធ័រ" ដែលមិនឆ្អែត	**Unroasted iron pyrites**	kg	15	0	10	0	
25.03	2503.00.00	ស្ពាន់ធ័រគ្រប់ប្រភេទមិនរាប់បញ្ចូលនូវស្ពាន់ធ័រ កករស្ពាន់ធ័រ និងស្ពាន់ធ័រអង្គិល	**Sulphur of all kinds, other than sublimed sulphur, precipitated sulphur and colloidal sulphur.**	kg	15	0	10	0	
25.04		ត្បូងក្រាហ្វិតធម្មជាតិ	**Natural graphite**						
	2504.10.00	- ជាម្សៅ ឬជាចំរៀកស្តើងៗ	- In powder or in flakes	kg	15	0	10	0	
	2504.90.00	- ផ្សេងទៀត	- Other	kg	15	0	10	0	
25.05		ដីខ្សាច់ធម្មជាតិគ្រប់ប្រភេទ ទោះបីមានឬគ្មានពណ៌ លើកលែងតែខ្សាច់មានជាតិលោហៈ នៃជំពូក ២៦ ។	**Natural sands of all kinds, whether or not coloured, other than metal-bearing sands of Chapter 26.**						
	2505.10.00	- ខ្សាច់ស៊ីលីកាត និងត្បូង	- Silica sands and quartz sands	kg	15	0	10	0	
	2505.90.00	- ផ្សេងទៀត	- Other	kg	15	0	10	0	

25.06		ក្វាត (ក្រៅពីខ្សាច់ធម្មជាតិ) ថ្មក្វាតស៊ីត ទោះបីជាដុំតូច ឬបំបែកព្រៀកក៏ដោយ ដោយអារ ឬ ដោយវិធីផ្សេង ជាផ្ទាំង ឬជាបន្ទះសំប៉ែតបួនជ្រុងស្មើ ឬ ទ្រវែង ។	**Quartz (other than natural sands); quartzite, whether or not roughly trimmed or merely cut, by sawing or otherwise, into blocks or slabs or a rectangular (including square) shape.**							
	2506.10.00	- ខ្សាច់ក្វាត	- Quartz	kg	15	0	10	0		
	2506.20.00	- ថ្មក្វាតស៊ីត	- Quartzite	kg	15	0	10	0		
25.07	2507.00.00	ដីកៅឡាំង និងដីប្រភេទកៅឡាំងផ្សេងទៀតទោះជាដុតបន្សុះ ឬមិនដុតបន្សុះក៏ដោយ ។	**Kaolin and other kaolinic clays whether or not calcined.**	kg	15	0	10	0		
25.08		ដីឥដ្ឋផ្សេងទៀត (លើកលែងតែដីឥដ្ឋរីករាលធំ (Expanded) ទីតាំងលេខ ៦៨.០៦) ដីឥដ្ឋអង់ដាលូស៊ីត ស៊ីយ៉ានីត ស៊ីលីម៉ានីត ទោះជាដុតបន្សុះ ឬមិនដុតបន្សុះក៏ដោយ មុល្លីត ដីឥដ្ឋហ្សាម៉ុត ឬឌីណា (chamotte or dinas) ។	**Other clays (not including expanded clays of heading No. 68.06), andalusite, kyanite and sillimanite, whether or not calcined, mullite; chamotte or dinas earths.**							
	2508.10.00	- ដីឥដ្ឋ Bentonite	- Bentonite	kg	15	0	10	0		
	2508.30.00	- ដីឥដ្ឋដុត	- Fire-clay	kg	15	0	10	0		
	2508.40.00	- ដីឥដ្ឋ ប្រភេទផ្សេងទៀត	- Other clays	kg	15	0	10	0		
	2508.50.00	- ដីឥដ្ឋអង់ដាលូស៊ីត គីយ៉ានីត ស៊ីលីម៉ានីត	- Andalusite, kyanite and sillimanite	kg	15	0	10	0		
	2508.60.00	- ដីឥដ្ឋ មូល្លីត	- Mullite	kg	15	0	10	0		
	2508.70.00	- ដីឥដ្ឋ ហ្សាម៉ុត ឬឌីណា	- Chamotte or dinas earths	kg	15	0	10	0		
25.09	2509.00.00	ដីស "សំណប់ជាវត្ថុធាតុដើម"	**Chalk.**	kg	15	0	10	0		
25.10		កាល់ស្យូមហ្វូស្វាតធម្មជាតិ ហ្វូស្វាតអាលុយមីញ៉ូមកាល់ស៊ីតធម្មជាតិ និងដីសហ្វូស្វាត ។	**Natural calcium phosphates, natural aluminium calcium phosphates and phosphatic chalk.**							
	2510.10	- មិនមែនជាកាក	- Unground:							
	2510.10.10	- - អាប៉ាទីត	- - Apatite	kg	15	0	10	0		

	2510.10.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
	2510.20	- ជាកាក :	- Ground:						
	2510.20.10	- - អាប៉ាទីត	- - apatite	kg	15	0	10	0	
	2510.20.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
25.11		បារីយ៉ូមស៊ុលហ្វាត (បារីទីន) បារីយ៉ូម កាបូណាតធម្មជាតិ (វីតេរីត) ទោះជាដុតបន្សុះ ឬមិនដុតបន្សុះក៏ដោយលើកលែងតែបារីយ៉ូមអុកស៊ីដនៅក្នុងទីតាំងលេខ២៨.១៦ ។	**Natural barium sulphate (barytes); natural barium carbonate (witherite), whether or not calcined, other than barium oxide of heading No. 28.16.**						
	2511.10.00	- បារីយ៉ូមស៊ុលហ្វាតធម្មជាតិ	- Natural barium sulphate (barytes)	kg	15	0	10	0	
	2511.20.00	- បារីយ៉ូមកាបូណាតធម្មជាតិ	- Natural barium carbonate (witherite)	kg	15	0	10	0	
25.12	2512.00.00	ម្សៅស៊ីលីសហ្វូស៊ីល ,Kieselguhr (ទ្រីប៉ូលីត និយ៉ាតូមិតជាដើម)និងដីស៊ីលីសដូចគ្នាដែលមានដង់ស៊ីតេប្រហាក់ប្រហែលមិនលើសពី ១ ទោះបីជាដុតបន្សុះ ឬមិនដុតបន្សុះក៏ដោយ ។	**Siliceous fossil meals (for exemple, kieselguhr, tripolite and diatomite) and similar siliceous earths, whether or not calcined, of an apparent specific gravity of 1 or less.**	kg	15	0	10	0	
25.13		ថ្មពង ថ្មខាត់ ថ្មក្រាំងដុះធម្មជាតិ ពណ្ណកថ្មត្បូង ក្រានិតធម្មជាតិ និងពណ្ណកថ្មដុសធម្មជាតិ ផងទៀតទោះបីទទួលការកែច្នៃដោយកំដៅក៏ដោយ ។	**Pumice stone; emery; natural corundum, natural garnet and other natural abrasives, whether or not heat-treated.**						
		- ថ្មប្រហោងពីកំអែភ្នំភ្លើង :	- Pumice stone :						
	2513.10.00	- - មិនទាន់យកមកកែច្នៃ ឬជាកុងទំរង់មិនប្រក្រតី រួមទាំងថ្មខាត់ជាកំទេច	- - Crude or in irregular pieces, including crushed pumice (bimskies)	kg	15	0	10	0	
	2513.20.00	- ថ្មខាត់ ថ្មក្រាំងដុះធម្មជាតិ ពណ្ណកថ្មត្បូងគ្រីណាតធម្មជាតិ និងពណ្ណកថ្មដុសធម្មជាតិផងទៀត	- Emery natural corundum, natural garnet and other natural abrasives	kg	15	0	10	0	

25.14	2514.00.00	ថ្មក្តារឈ្មួនទោះបីជាផ្ទាំងតូច ឬបំបែកផ្សេងទៀតដោយអារ ឬវិធីផ្សេងទៀត សំរាប់សំណង់ ។	**Slate, whether or not roughly trimmed or merely cut, by sawing or otherwise, into blocks or slabs of a rectangular (including square) shape.**	kg	7	0	10	0	
25.15		ថ្មកែវ ថ្មកំបោរ ក្រាវែរតាំង ថ្មអេគូស៊ីន និងថ្មកំបោរសំរាប់លាងផ្សេងទៀត ថ្មកំបោរសំរាប់សាងសង់ ដែលមានទម្ងន់មានប្រហាក់ប្រហែល ឬលើស ២.៥ និងថ្មកែវអាលបាត្រ ទោះបីជាតុំតូច ឬបំបែកដោយអារ ឬវិធីផ្សេងទៀតជាផ្ទាំង ឬជាបន្ទះបួនជ្រុងស្មើ ឬទ្រវែង ។	**Marble, travertine, ecaussine and other calcareous monumental or building stone of an apparent specific gravity of 2.5 or more, and alabaster, whether or not roughly trimmed or merely cut, by sawing or otherwise, into blocks or slabs of a rectangular (including square) shape.**						
		- ថ្មកែវ និងថ្មកំបោរ Travertine :	- Marble and travertine :						
	2515.11.00	- - មិនទាន់ច្នៃ ឬធ្វើអោយគគ្រាត	- - Crude or roughly trimmed	kg	7	0	10	0	
	2515.12	- - គ្រាន់តែកាត់ផ្សេងទៀតដោយអារនិងណោឬជាដុំឬជាបន្ទះរាងចតុកោណកែងជាការេផង	- - Merely cut, by sawing or otherwise, into blocks or slabs of a rectangular (including square) shape						
	2515.12.10	- - - ដុំ	- - - Blocks	kg	7	0	10	0	
	2515.12.20	- - - បន្ទះ	- - - Slabs	kg	7	0	10	0	
	2515.20.00	- ថ្មអេគូស៊ីន ថ្មកំបោរសំរាប់លាងផ្សេងទៀត ថ្មកំបោរសំរាប់សាងសង់ថ្ម alabaster	- Ecaussine and other calcareous monumental or building stone ; alabaster	kg	7	0	10	0	
25.16		ក្កកថ្មភ្នំ ពកហៀរ បាសាល់ ថ្មសំលៀង និងថ្មផ្សេងទៀត សំរាប់សំណង់ទោះបីជា ដុំតូចធំដោយអារ ឬវិធីផ្សេង ជាផ្ទាំង ឬបន្ទះបួនជ្រុងស្មើ ឬទ្រវែង ។	**Granite, porphyry, basalt, sandstone and other monumental or building stone, whether or not roughly trimmed or merely cut, by sawing or otherwise, into blocks or slabs of a rectangular (including square) shape.**						
		- ថ្មក្រានីត :	- Granite :						
	2516.11.00	- - មិនទាន់ច្នៃ ឬធ្វើអោយគ្រាត	- - Crude or roughly trimmed	kg	7	0	10	0	
	2516.12	- - គ្រាន់តែកាត់ផ្សេងទៀតដោយអារនិងណោ ឬក៏ជាដុំ ឬជាបន្ទះរាងចតុកោណកែងជាការេផង :	- - Merely cut, by sawing or otherwise, into blocks or slabs of a rectangular (including square) shape:						
	2516.12.10	- - - ដុំ	- - - Blocks	kg	7	0	10	0	

	2516.12.20	- - - បន្ទះ	- - - Slabs	kg	7	0	10	0	
	2516.20.00	- ថ្មភក់	- Sandstone	kg	7	0	10	0	
	2516.90.00	- ថ្មសំរាប់សាងសង់ផ្សេងទៀត	- Other monumental or building stone	kg	7	0	10	0	
25.17		គ្រួសថ្មអាចម៍ផ្កាយតូច ធំ ថ្មបំបែកហើយ ដែលជាទូទៅសំរាប់ចាក់បេតុង និងក្រាលថ្នល់ ក្រាលផ្លូវដែក ឬក្រាលផ្សេងទៀត គ្រួស និងស៊ីឡិច ទោះបីជាកែច្នៃដោយកំដៅ ថ្មក្រាល ម៉ាកាដាម អាចម៍លោហធាតុឈាយ ឬសំណល់ឧស្សាហកម្មប្រហាក់ប្រហែល ទោះជាវានៅក្នុងរូប ធាតុនៃភាគខាងលើក៏ដោយ ថ្មលាយកៅស៊ូក្រាលថ្នល់ជាគ្រាប់ល្អិត ឬជាអំបែង និងជាម្សៅថ្ម ក្នុងទីតាំងលេខ ២៥.១៥ ឬ ២៥.១៦ ដែល កែច្នៃដោយកំដៅ ។	**Pebbles, gravel, broken or crushed stone, of a kind commonly used for concrete aggregates, for road metalling or for railway or other ballast, shingle and flint, whether or not heat-treated; macadam of slag, dross or similar industrial waste, whether or not incorporating the materials cited in the first part of the heading; tarred macadam; granules, chippings and powder, of stones of heading No. 25.15 or 25.16, whether or not heat-treated** .						
	2517.10.00	- គ្រួស ថ្មអាចម៍ផ្កាយ តូចធំ ថ្មបំបែកហើយ ដែលជាទូទៅសំរាប់ចាក់បេតុង និងក្រាលថ្នល់ ក្រាលផ្លូវដែក ឬក្រាលផ្សេងទៀត គ្រួស និងស៊ីឡិច ទោះបីជាកែច្នៃដោយកំដៅ	- Pebbles, gravel, broken or crushed stone,of a kind commonly used for concrete aggregates, for road metalling or for railway or other ballast,shingle and flint, whether or not heat-treated	kg	7	0	10	0	
	2517.20.00	- ថ្មក្រាលម៉ាកាដាម អាចម៍លោហៈធាតុឈាយ ឬ សំណល់ឧស្សាហកម្មប្រហាក់ប្រហែល ទោះជានៅក្នុងរូបធាតុនៃទីតាំងរងលេខ ២៥១៧.១០	- Macadam of slag, dross or similar industrial waste, whether or not incorporating the materials cited in subheading No. 2517.10	kg	7	0	10	0	
	2517.30.00	- ថ្មលាយកៅស៊ូក្រាលថ្នល់	- Tarred Macadam	kg	7	0	10	0	
		- ជាគ្រាប់ល្អិត ជាអំបែង និងជាម្សៅថ្មនៃទីតាំងលេខ ២៥.១៥ ឬ ២៥.១៦ ទោះបីជាកែច្នៃ ឬមិនកែច្នៃក៏ដោយ :	- Granules, chippings and powder, of stones of heading No.25.15or25.16, whether or not heat-treated :						
	2517.41.00	- - នៃថ្មម៉ាប	- - Of marble	kg	7	0	10	0	
	2517.49.00	- - ផ្សេងទៀត	- - Other	kg	7	0	10	0	

25.18		ថ្មដូឡូមីត ទោះបីដុតស្ងួត ឬដុតរលាយ ថ្មដូឡូមីតឆ្លូត ធំបានមកពីការកាត់ ឬវិធីផ្សេងទៀតជាផ្ទាំង ឬជាបន្ទះរាងបួនជ្រុងស្មើ ឬទ្រវែង ថ្មដូឡូមីត ដោយជាន់ឱ្យស្អិតសំរាប់សាងសង់ ។	**Dolomite, whether or not calcined or sintered;including dolomite roughly trimmed or merely cut, by sawing or otherwise, into blocks or slabs of a rectangular (including square) shape; dolomite ramming mix.**						
	2518.10.00	- ថ្មដូឡូមីតមិនដុតឱ្យស្ងួត	- Dolomite not calcined or sintered	kg	15	0	10	0	
	2518.20.00	- ថ្មដូឡូមីតដែលដុតស្ងួត	- Calcined or sintered dolomite	kg	15	0	10	0	
	2518.30.00	- ថ្មដូឡូមីត ដែលជាន់ឱ្យស្អិតសំរាប់សាងសង់ (ថ្មដូឡូមីតលាយកៅស៊ូក្រាលថ្នល់)	- dolomite ramming mix	kg	15	0	10	0	
25.19		ម៉ាញ៉េស្យូមកាបូណាតធម្មជាតិ(ម៉ាញ៉េស៊ីត)ម៉ាញ៉េស្យូមរលាយដោយអគ្គិសនី ឬដុតរលាយ ទោះបីមានបរិមាណតិចតួចនៃអុកស៊ីតដទៃទៀតបន្ថែមមុនពេល ដុតរលាយក៏ដោយ ម៉ាញ៉េស្យូមអុកស៊ីតដទៃទៀតទោះបីសុទ្ធឬមិនសុទ្ធក៏ដោយ ។	**Natural magnesium carbonate (magnesite); fused magnesia; dead-burned (sintered) magnesia, whether or not containing small quantities of other oxides added before sintering; other magnesium oxide, whether or not pure.**						
	2519.10.00	- ម៉ាញ៉េស្យូមកាបូណាតធម្មជាតិ	- Natural magnesium carbonate (magnesite)	kg	15	0	10	0	
	2519.90.00	- ផ្សេងទៀត	- Other	kg	15	0	10	0	
25.20		ថ្មហ្ស៊ីប(ម្នាងសិលា)អានីទ្រីត ថ្មស្អិតទោះបីលាយពណ៌ បន្ថែមសារធាតុពន្លឿនឬពន្យឺតភាពរឹង ។	**Gypsum; anhydrite; plasters (consisting of calcined gypsum or calcium sulphate) whether or not coloured, with or without small quantities of accelerators or retarders.**						
	2520.10.00	- ថ្មហ្ស៊ីប អានីទ្រីត	- Gypsum , anhydrite	kg	7	0	10	0	
	2520.20	- ម្នាងសិលាម្សៅ (plasters) :	- Plasters:						
	2520.20.10	- - សំរាប់ប្រើក្នុងវិជ្ជាទន្តពេទ្យ	- - For use in dentistry	kg	7	0	10	0	
	2520.20.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
25.21	2521.00.00	ថ្មកំបោរកាសទឹក ថ្មសំរាប់ធ្វើកំបោរ ឬស៊ីម៉ង់ត៍	**Limestone flux; limestone and other calcareous stone, of a kind used for the manufacture of lime or cement.**	kg	7	0	10	0	

25.22		ថ្មកំបោររស់ ថ្មកំបោរងាប់ និងថ្មកំបោរប្រើក្នុងទឹក លើកលែងតែ កាល់ស្យូម អុកស៊ីត ឬអ៊ីដ្រុកស៊ីដចេញនៅក្នុងទីតាំងលេខ ២៨.២៥ ។	**Quicklime, slaked lime and hydraulic lime, other than calcium oxide and hydroxide of heading No. 28.25.**						
	2522.10.00	- ថ្មកំបោររស់	- Quicklime	kg	7	0	10	0	
	2522.20.00	- ថ្មកំបោរងាប់	- Slaked lime	kg	7	0	10	0	
	2522.30.00	- ថ្មកំបោរប្រើក្នុងទឹក	- Hydraulic lime	kg	7	0	10	0	
25.23		ស៊ីម៉ងត៍ទឹក " ប្រើក្នុងទឹក " រាប់បញ្ចូលទាំងស៊ីម៉ងត៍មិនទាន់កិន ទោះបីលាយពណ៌ក៏ដោយ ។	**Portland cement, aluminous cement, slag cement, supersulphate cement and similar hydraulic cements, whether or not coloured or in the form of clinkers.**						
	2523.10	- ស៊ីម៉ងត៍គ្រើម clinkers +	- Cement clinkers:						
	2523.10.10	- - ស៊ីម៉ងត៍ស	- - For white cement	kg	15	0	10	0	
	2523.10.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
		- ស៊ីម៉ងត៍ម្សៅ portland +	- Portland cement :						
	2523.21.00	- - ស៊ីម៉ងត៍ស ទោះបីជាដាក់ពណ៌តាមបែបសិប្បនិម្មិតក៏ដោយ	- - White Cement, whether or not artificially coloured	kg	15	0	10	0	
	2523 29	- - ផ្សេងទៀត :	- - Other:						
	2523.29.10	- - - ស៊ីម៉ងត៍ពណ៌	- - - Colour cement	kg	15	0	10	0	
	2523.29.90	- - - ផ្សេងទៀត	- - - Other	kg	15	0	10	0	
	2523.30.00	- ស៊ីម៉ងត៍មានជាតិអាលុយមីញ៉ូម	- Aluminous Cement	kg	15	0	10	0	
	2523.90.00	- ស៊ីម៉ងត៍ ប្រើក្នុងទឹកដទៃទៀត	- Other Hydraulic cements	kg	15	0	10	0	
25.24		អាមីញ៉ង់ ។	**Asbestos.**						
	2524.10.00	- ក្រូស៊ីដូលីត	- Crocidolite	kg	7	0	10	0	
	2524.90.00	- ផ្សេងទៀត	- Other	kg	7	0	10	0	
25.25		ថ្មមីកា រាប់បញ្ចូលទាំងមីកាបន្ទះមិនស្មើគ្រង [splitting] សំណល់មីកា	**Mica, including splittings; mica waste.**						
	2525.10.00	- ថ្មមីកាមិនទាន់ច្នៃ និងថ្មមីកាជាសន្លឹក ឬជាបន្ទះមិនស្មើគ្រង	- Crude mica and mica rifted into sheets or splittings	kg	7	0	10	0	

	2525.20.00	- ម្សៅថ្មមីកា	- Mica powder	kg	7	0	10	0		
	2525.30.00	- កាកសំណល់មីកា	- Mica waste	kg	7	0	10	0		
25.26		ថ្មស្តេអាទីតធម្មជាតិ ទោះបីជាធ្វើឱ្យទៅគ្រួច ឬបំបែកទៀត បានមកពី ការអារ ឬវិធីផ្សេង ជាផ្ទាំង ឬបន្ទះបួនជ្រុងស្មើ ឬទ្រវែង ថ្មតាល់ ។	**Natural steatite, whether or not roughly trimmed or merely cut, by sawing or otherwise, into blocks or slabs of a rectangular (including square) shape;talc.**							
	2526.10.00	- មិនបំបែក មិនកិនជាម្សៅ	- not crushed, not powdered	kg	15	0	10	0		
	2526.20	- បំបែក ឬកិនជាម្សៅ :	- crushed or powdered:							
	2526.20.10	- - ម្សៅតាល់	- - Talc powder	kg	15	0	10	0		
	2526.20.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0		
25.28		អំបិលបូរ៉ាតធម្មជាតិ ឬល្បាយខាប់របស់វា (ដុតស្ងួត ឬមិនដុត) លើកលែងតែ បូរ៉ាត ចំរាញ់យកពីសិលាមានជាតិអំបិល អាស៊ីតបូរិក ធម្មជាតិ ដែលមាន កំហាប់អតិបរិមា អាស៊ីត ៨៥ % នៃ H_3BO_3 លើផលិតផលស្ងួត ។	**Natural borates and concentrates thereof (whether or not calcined), but not including borates separated from natural brine; natural boric acid containing not more than 85 % of H3B03 calculated on the dry weight.**							
	2528.10.00	- អំបិលសូដ្យូមបូរ៉ាតធម្មជាតិ និងល្បាយខាប់របស់វា (ទោះបីដុតស្ងួត ឬដុតមិនស្ងួតក៏ដោយ) ។	- Natural sodium borates and concentrates thereof (whether or not calcined)	kg	15	0	10	0		
	2528.90.00	- ផ្សេងទៀត	- Other	kg	15	0	10	0		
25.29		ហ្វែលស្ប៉ាត ឡឺស៊ីត ណេហ្វិលីន និងថ្មណេហ្វិលីនស៊ីយ៉េនីត ស្ប៉ាតហ្លុយអ័រ	**Felspar; leucite; nepheline and nepheline syenite;fluorspar.**							
	2529.10.00	- ហ្វែលស្ប៉ាត	- Felspar	kg	15	0	10	0		
		- ស្ប៉ាតហ្លុយអ័រ :	- Fluorspar :							
	2529.21.00	- - មានកាល់ស្យូមហ្លុយអ័រទំងន់ត្រឹម ៩៧ % ឬតិចជាងនេះ	- - Containing by weight 97 % or less of calcium fluoride	kg	15	0	10	0		
	2529.22.00	- - មានកាល់ស្យូមហ្លុយអ័រទំងន់លើសពី ៩៧ %	- - Containing by weight more than 97 % of calcium fluoride	kg	15	0	10	0		
	2529.30.00	- ឡឺស៊ីត ណេហ្វិលីន និងថ្មណេហ្វិលីនស៊ីយ៉េនីត	- Leucite, nepheline and nepheline syenite	kg	15	0	10	0		

25.30		វត្ថុធាតុរ៉ែដែលគ្មានឈ្មោះ និងមិនរាប់បញ្ចូលនៅកន្លែងផ្សេងទៀត	**Mineral substances not elsewhere specified or included.**						
	2530.10.00	- វែមីគុយលីត ពែលីត និងក្លរីត	- Vermiculite, perlite and chlorites, unexpanded	kg	15	0	10	0	
	2530.20	- គីសេរីត អិបសូមីត (ម៉ាញ៉េស្យូមស៊ុលហ្វាតធម្មជាតិ) :	- Kieserite, epsomite (natural magnesium sulphates):						
	2530.20.10	- - គីសេរីត	- - Kieserite	kg	15	0	10	0	
	2530.20.20	- - អិបសូមីត	- - Epsomite	kg	15	0	10	0	
	2530.90.00	- - ផ្សេងទៀត	- - Other	kg	15	0	10	0	

ជំពូកទី ២៦

រ៉ែ អាចម៍លោហៈ និង ផេះ

Chapter 26

Ores, slag and ash

កំណត់សំគាល់

Notes

1.- ជំពូកនេះមិនរាប់បញ្ចូល :

This Chapter does not cover :

(a) កាកសំណល់លោហកម្ម និងកាកសំណល់ឧស្សាហកម្មប្រហាក់ប្រហែល ដែលផ្សំជាម៉ាកាដាម "ទីតាំងលេខ ២៥.១៧" ។

Slag or similar industrial waste prepared as macadam (heading No. 25.17);

(b) ម៉ាញ៉េស្យូមកាបូណាតធម្មជាតិ (Magnésie) ទោះបីដុតសុសឬមិនដុតក៏ដោយ ទីតាំងលេខ ២៥.១៩ ។

Natural magnesium carbonate (magnesite), whether or not calcined (heading No. 25.19);

(c) កាកលោហកម្មនៃជំពូក ៣១ ។

Basic slag of Chapter 31;

(d) អាចម៍លោហកម្ម អាចម៍សិលា និងអាចម៍រ៉ែប្រហាក់ប្រហែល "ទីតាំងលេខ ៦៨.០៦" ។

Slag wool, rock wool or similar mineral wools (heading No. 68.06);

	(e)	កាកសំណល់ និងកំទេចនៃលោហធាតុមានតំលៃ ឬលោហធាតុដែលស្រោបដោយលោហធាតុមានតំលៃ ។ កាកសំណល់ និងកំទេចដទៃទៀត ដែលមានលាយលោហធាតុមានតំលៃ ឬល្បាយលាយជាមួយ លោហធាតុមានតំលៃនៃប្រភេទប្រើប្រាស់ជាពិសេសសំរាប់ទាញយក លោហធាតុមានតំលៃមកវិញ (ទីតាំងលេខ ៧១.១២) ។	Waste or scrap of precious metal or of metal clad with precious metal; other waste or scrap containing precious metal or precious metal compounds, of a kind used principally for the recovery of precious metal (heading No. 71.12); or
	(f)	សារជាតិដំបូងនៃទង់ដែងលាយនៃនីកែល និងកូបាលក៏បានមកពីការរំលាយរ៉ែ (ផ្នែកទី XV) ។	Copper, nickel or cobalt mattes produced by any process of smelting (Section XV).
2.-		តាមអត្ថន័យទីតាំងលេខ ២៦.០១ ដល់ ២៦.១៧ ដែលហៅថារ៉ែគឺរ៉ែប្រភេទស្ថិតក្នុងរ៉ែវិទ្យា ដែលបានយកមកប្រើប្រាស់ក្នុងផ្នែកលោហកម្ម សំរាប់ផ្ចាច់បារ៉ត នៃលោហៈនៃទីតាំងលេខ ២៨.៤៤ ឬ ពីលោហៈនៃផ្នែកទី XIV ឬ XV នោះទោះបីជារ៉ែទាំងនោះសំរាប់យកទៅប្រើ ក្នុងគោលបំណងនៃទីតាំងលេខ ២៦.០១ ទៅ ២៦.១៧ មិនមែនលោហកម្មក៏ដោយ ប៉ុន្តែក្នុងលក្ខខណ្ឌដែលរ៉ែទាំងនោះមិនបានទទួលការកែច្នៃផ្សេង អំពីវិធីដែលបានធ្វើមិនធម្មតាសំរាប់រ៉ែ នៃឧស្សាហកម្មលោហធាតុ ។	For the purposes of headings Nos. 26.01 to 26.17, the term "ores" means minerals of mineralogical species actually used in the metallurgical industry for the extraction of mercury, of the metals of heading No. 28.44 or of the metals of Section XIV or XV, even if they are intended for non-metallurgical purposes. Headings Nos. 26.01 to 26.17 do not, however, include minerals which have been submitted to processes not normal to the metallurgical industry.
3.-		រាប់ចូលក្នុងទីតាំងលេខ ២៦.២០ តែចំពោះ :	Heading 26.20 applies only to:
	(a)	ផេះ ឬសំណល់ជាប្រភេទប្រើក្នុង ឧស្សាហកម្មសំរាប់ទាញយកលោហធាតុ ឬការផលិតនូវធាតុផ្សំលោហធាតុ លើកលែង ផេះ និងសំណល់ពីការដុតកាកសំណល់តាមទីក្រុង (ទីតាំង ២៦.២១)	Ash and residues of a kind used in industry either for the extraction of metals or as a basis for the manufacture of chemical compounds of metals,excluding ash and residues from the incineration of municipal waste (heading 26.21);and
	(b)	ផេះ និងសំណល់មានអាសេនិក ទោះមាន ឬមិនមានលោហធាតុ ត្រូវបានប្រើប្រាស់គ្រប់ប្រភេទទោះបានពីអាសេនិក ឬ លោហធាតុ ឬពីការផលិតសមាសធាតុគីមីរបស់វា ។	Ash and residues containing arsenic, whether or not containing metals, of a kind used either for the extraction of arsenic or metals or for the manufacture of their chemical compounds.

កំណត់សំគាល់ទីតាំងរង

Subheading Note

1.- ទីតាំងរង ២៦២០.២១ ភក់នៃប្រេងសាំងមានសំណ និងភក់នៃល្បាយប្រឆាំងការផ្ទុះដែលមានសំណ មានន័យថាជាភក់ដែលទទួលបានពីធុងស្តុកប្រេងសាំងដែលមានជាតិសំណ និងមានសមាសធាតុការពារជាតិសំណ (សំណតេត្រាអេទីល) និងរួមមានសំណ សមាសធាតុសំណ និង ដែកអុកស៊ីដ

For the purposes of subheading 2620.21, "leaded gasoline sludges and leaded anti-knock compound sludges" mean sludges obtained from storage tanks of leaded gasoline and leaded anti-knock compounds (for example, tetraethyl lead), and consisting essentially of lead, lead compounds and iron oxide.

2.- ផេះ និង សំណល់មានអាសេនិក បារត តាលីយ៉ូម ឬល្បាយរបស់វាប្រើប្រាស់ចំរាញ់ប្រភេទដែលបានពីអាសេនិក ឬលោហធាតុទាំងនោះ ឬផលិតកម្មនៃសមាសធាតុគីមីរបស់វា ត្រូវបានចាត់ថ្នាក់នៅទីតាំងរង ២៦២០.៦០

Ash and residues containing arsenic, mercury, thallium or their mixtures, of a kind used for the extraction of arsenic or those metals or for the manufacture of their chemical compounds, are to be classified in subheading 2620.60.

Head.	Tariff Code	រៀបរាប់មុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
26.01		រ៉ែដែក និងល្បាយខាប់របស់វារួមទាំងដែកពៀរីតដុត	**Iron ores and concentrates, including roasted iron pyrites**						
		- រ៉ែដែក និងល្បាយខាប់របស់វាក្រៅពីដែកពៀរីតដុត	- Iron ores and concentrates, other than roasted iron pyrites :						
	2601.11.00	- - មិនប្រមូលផ្តុំគ្នា	- - Non-agglomerated	kg	7	0	10	0	
	2601.12.00	- - ប្រមូលផ្តុំគ្នា	- - Agglomerated	kg	7	0	10	0	
	2601.20.00	- ដែកពៀរីតដុត	- Roasted iron pyrites	kg	7	0	10	0	
26.02	2602.00.00	រ៉ែម៉ង់កាណែស និងល្បាយខាប់របស់វារាប់បញ្ចូលទាំងរ៉ែដែកដែលមានជាតិម៉ង់កាណែសក្នុង ២០% ឬលើសពីនេះជាទម្ងន់លើផលិតផលស្ងួត ។	**Manganese ores and concentrates, including ferruginous manganese ores and concentrates with a manganese content of 20% or more, calculated on the dry weight.**	kg	7	0	10	0	
26.03	2603.00.00	រ៉ែទង់ដែង និងល្បាយខាប់របស់វា	**Copper ores and concentrates.**	kg	7	0	10	0	
26.04	2604.00.00	រ៉ែនីកែល និងល្បាយខាប់របស់វា	**Nickel ores and concentrates.**	kg	7	0	10	0	

26.05	2605.00.00	រ៉ែកូបាល់ និងល្បាយខាប់របស់វា	**Cobalt ores and concentrates.**	kg	7	0	10	0	
26.06	2606.00.00	រ៉ែអាលុយមីញ៉ូម និងល្បាយខាប់របស់វា	**Aluminium ores and concentrates.**	kg	7	0	10	0	
26.07	2607.00.00	រ៉ែសំណ និងល្បាយខាប់របស់វា	**Lead ores and concentrates.**	kg	7	0	10	0	
26.08	2608.00.00	រ៉ែស័ង្កសី និងល្បាយខាប់របស់វា	**Zinc ores and concentrates.**	kg	7	0	10	0	
26.09	2609.00.00	រ៉ែសំណប៉ាហាំង និងល្បាយខាប់របស់វា	**Tin ores and concentrates.**	kg	7	0	10	0	
26.10	2610.00.00	រ៉ែក្រូម និងល្បាយខាប់របស់វា	**Chromium ores and concentrates.**	kg	7	0	10	0	
26.11	2611.00.00	រ៉ែតង់ស្តែន និងល្បាយខាប់របស់វា	**Tungsten ores and concentrates.**	kg	7	0	10	0	
26.12		រ៉ែអ៊ុយរ៉ានីញ៉ូម ឬតូលីញ៉ូម និងល្បាយខាប់របស់វា	**Uranium or thorium ores and concentrates.**						
	2612.10.00	- រ៉ែអ៊ុយរ៉ានីញ៉ូម និងល្បាយខាប់របស់វា	- Uranium ores and concentrates	kg	7	0	10	0	
	2612.20.00	- រ៉ែតូលីញ៉ូម និងល្បាយខាប់របស់វា	- Thorium ores and concentrates	kg	7	0	10	0	
26.13		រ៉ែម៉ូលីបដែន និង ល្បាយខាប់របស់វា	**Molybdenum ores and concentrates.**						
	2613.10.00	- ដុត	- Roasted	kg	7	0	10	0	
	2613.90.00	- ផ្សេងទៀត	- Other	kg	7	0	10	0	
26.14		រ៉ែទីតាន និងល្បាយខាប់របស់វា	**Titanium ores and concentrates.**						
	2614.00.10	- រ៉ែអ៊ីលម៉េនីត និងល្បាយរបស់វា	- Ilmenite ores and concentrates	kg	7	0	10	0	
	2614.00.90	- ផ្សេងទៀត	- Other	kg	7	0	10	0	
